ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# នីតិវិធីប្រតិបត្តិការស្តង់ដារ នៃមជ្ឈមណ្ឌលប្រតិបត្តិការគ្រោះបន្ទាន់ និងប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

សីហា ២០១៩

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាបានបង្កើតច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានគោលដៅត្រៀមបង្ការ បន្ធូរ កាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិ និងដោយមនុស្ស ព្រមទាំងឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ និងស្តារឡើងវិញក្រោយគ្រោះមហន្តរាយ។ ច្បាប់នេះតំរូវឲ្យក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល បង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួងស្ថាប័នរបស់ខ្លួន និងត្រូវចាត់ឲ្យមាន មន្ត្រីបង្គោលដើម្បីសំរបសំរួល និងធ្វើការប្រាស្រ័យទាក់ទងជាប្រចាំ ជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ។

ដោយអនុលោមតាមច្បាប់ខាងលើ និងដើម្បីឆ្លើយតបទៅនឹងគ្រោះអាសន្នផ្នែកសុខភាពសាធារណៈ ដែលជាផ្នែកមួយនៃ គ្រោះអាសន្នអាចបង្កគ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលអាចប៉ះពាល់ដល់សុខភាពអាយុជីវិតប្រជាជន ទេសចរណ៍ និងសេដ្ឋកិច្ច ជាតិ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយអង្គការ សុខភាពពិភពលោក បានរៀបចំចងក្រងនូវនីតិវិធីប្រតិបត្តិការស្តង់ដារ សំរាប់ឆ្លើយតបទៅនឹងគ្រោះអាសន្នផ្នែកសុខភាព សាធារណៈ ដែលអាចអនុវត្តបាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យ៉ាងណាមិញ ការងារគ្រោះអាសន្នផ្នែកសុខភាព សាធារណៈ មិនមែនមានតែនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងមួយទេ ដែលអាចឆ្លើយតប នូវរាល់គ្រោះបន្ទាន់ផ្នែកសុខភាព នៅក្នុងប្រទេសកម្ពុជាបាន គឺតំរូវឲ្យមានការចូលរួមពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ដែលពាក់ព័ន្ធផ្សេងទៀត រួមទាំងអ្នក ជំនាញផ្នែកប្រយុទ្ធនឹងជំងឺឆ្លង នៅថ្នាក់មូលដ្ឋានផងដែរ។

នីតិវិធីប្រតិបត្តិការស្តង់ដារសំរាប់គ្រោះបន្ទាន់នេះ នឹងកំនត់នូវតួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺ ឆ្លង និងមន្ត្រីនានានៅក្នុងគ្រោះបន្ទាន់ទំហំធំ ក៏ដូចជាតួនាទី ក្រសួង ស្ថាបន័ ដៃគូអភិវឌ្ឍន៍ និងការទទួលខុសត្រូវនៅថ្នាក់ ខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យ និងមណ្ឌលសុខភាព។ ឯកសារនេះក៏មានភ្ជាប់ផងដែរនូវទំរង់ការនានា សំរាប់ជាជំនួយដល់ បុគ្គលិក ក្នុងការធ្វើផែនការ ការអនុវត្ត និងរៀបចំឯកសារនៃការងាររបស់ពួកគេ។

នីតិវិធីប្រតិបត្តិការស្តង់ដារនេះនឹងត្រូវអនុវត្ត (សកម្ម) នៅពេលណាដែលព្រឹត្តិការណ៍សុខភាពសាធារណៈ តំរូវឲ្យមានការ ឆ្លើយតបលើសពីការងារប្រចាំថ្ងៃរបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ឬនៅពេលមានការកំណត់ពីថ្នាក់ដឹកនាំរបស់ក្រសួង សុខាភិបាល។

ថ្ងៃ ពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ សីហា ឆ្នាំ ២០១៩

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង_ហួត

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណចំពោះ លោក លោកស្រី និងមន្ត្រីបច្ចេកទេសអង្គការសុខភាពពិភពលោក ដែលបានជួយគាំទ្រក្នុងការបង្កើត និងបញ្ចប់ នីតិវិធីប្រតិបត្តិការស្តង់ដារ មជ្ឈមណ្ឌលប្រតិបត្តិការគ្រោះបន្ទាន់ និងប្រពន្ធ័គ្រប់គ្រងឧប្បត្តិហេតុ ដែលមានមូលដ្ឋាននៅក្នុងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល ប្រទេសកម្ពុជា។

| | |
|---|---|
| **លោកវេជ្ជ. លី សូវ៉ាន់** | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| **លោកស្រីវេជ្ជ. តេង ស្រី** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| **លោក សុខ សំណាង** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| **លោកវេជ្ជ. កប វណ្ណដា** | មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក |
| **លោកស្រី** Stephanie WHEELER | មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក |
| **លោកស្រី** Amy Elizabethy PARRY | មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក |
| **លោក អៀង វណ្ណារ៉ា** | មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក |
| **លោកស្រី** Vicky HOUSSIERE | មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក។ |

## មាតិកា


**ពាក្យគន្លឹះ និងអក្សរកាត់**........5
**សេចក្តីផ្តើម**........6
**គោលបំណង និងវត្ថុបំណងនៃឯកសារនេះ**........6
**វិសាលភាព**........7
**អ្នកប្រើប្រាស់ឯកសារនេះ**........8
**ឯកសារគាំទ្រ**........8
**សមាសធាតុសំខាន់ៗរបស់** EOC........8
EOC **នៅក្នុងប្រទេសកម្ពុជា**........9
រូបភាពទី១៖ ផែនទីទីតាំង EOC នៅកម្ពុជា........9
**ការគ្រប់គ្រងបន្ទប់** EOC........11
តារាងទី ១៖ សកម្មភាពសំខាន់ៗរបស់អ្នកគ្រប់គ្រង EOC........11
EOC **នៅក្នុងគ្រាបន្ទាន់អាសន្ន**........12
**ការដាក់ឱ្យដំណើរការ** EOC........12
តារាងទី ២៖ កម្រិតដាក់ឱ្យដំណើរការ EOC........13
**អ្វីដែលអាចកើតឡើង នៅពេលនៃការដាក់ឱ្យដំណើរការ**........13
តារាងទី ៣៖ កត្តានានាដែលអាចជំរុញការដាក់ឱ្យដំណើរការ EOC........14
**សកម្មភាពសំខាន់របស់** EOC **បន្ទាប់ពីគ្រប់គ្រានដាក់ឱ្យដំណើរការ**........15
តារាងទី ៤៖ សកម្មភាពសំខាន់របស់ EOC នៅក្រោយការដាក់ឱ្យដំណើរការ........15
**ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ**........16
រូបភាពទី ២៖ រចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ........18
តារាងទី ៥៖ តួនាទីនៃមុខងារដឹកនាំសំខាន់ៗ........19
តារាងទី ៦៖ តួនាទីនៃមុខងារសម្របសម្រួលដៃគូ........20
តារាងទី ៧៖ តួនាទីនៃមុខងារព័ត៌មាន និងផែនការ........20
តារាងទី ៨៖ តួនាទីរបស់មុខងារប្រតិបត្តិការសុខភាព និងជំនាញបច្ចេកទេស........22
តារាងទី ៩៖ តួនាទីនៃមុខងារគាំទ្រប្រតិបត្តិការ និងភស្តុភារ........23
តារាងទី ១០៖ តួនាទីនៃមុខងារហិរញ្ញវត្ថុ និងរដ្ឋបាល........24
**ការបិទដំណើរការ** IMS **និង** EOC........24
**ការតាមដាន និងវាយតម្លៃ**........25

កំណត់ត្រាសកម្មភាព ........ 25
ការពិនិត្យឡើងវិញនៅក្រោយវិធានការ ........ 25
**ឧបសម្ព័ន្ធ** ........ 26
ឧបសម្ព័ន្ធ ១៖ តារាងធនធានដឹកនាំ ........ 26
ឧបសម្ព័ន្ធ ២៖ បញ្ជីទំនាក់ទំនងអ្នកឯកទេសតាមប្រភេទគ្រោះថ្នាក់ ........ 27
១. ជំងឺឆ្លង ........ 27
២. គ្រោះមហន្តរាយធម្មជាតិ ........ 28
៣. ពុលចំណីអាហារ (Foodborne Outbreak Response Team (FORT)) ........ 29
៤. Zoonotic ........ 30
៥. AMR ........ 30
៦. AET (ក្រុម 1-7) ........ 33
ឧបសម្ព័ន្ធ ៣៖ ទម្រង់គំរូ IMS ដែលត្រូវបំពេញនៅក្នុងពេលដាក់ឱ្យដំណើរការ ........ 37
ឧបសម្ព័ន្ធ ៤៖ រចនាសម្ព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ បែងចែកតាមប្រភេទគ្រោះថ្នាក់ ........ 38
ឧបសម្ព័ន្ធ ៥៖ គោលការណ៍ណែនាំ អំពីវិធានការបែងចែកទៅតាមពេលវេលា និងមុខងារសំខាន់ ........ 40
ឧបសម្ព័ន្ធ ៦៖ សន្លឹកកិច្ចការមុខងារសំខាន់ ........ 46

# ពាក្យគន្លឹះ និងអក្សរកាត់

| | |
|---|---|
| AAR | ការពិនិត្យឡើងវិញនៅក្រោយវិធានការ |
| CamEWARN | ប្រព័ន្ធតាមដានជំងឺឆ្លងរបស់កម្ពុជា |
| CDC | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| **គ្រោះអាសន្ន** | ការគំរាមកំហែងជាក់ស្តែងណាមួយចំពោះសុខភាព និង/ឬសុវត្ថិភាពសាធារណៈ ដែលទាមទារនូវអន្តរាគមន៍បន្ទាន់ |
| EMT | ក្រុមគ្រប់គ្រងគ្រោះបន្ទាន់ |
| EOC | មជ្ឈមណ្ឌលប្រតិបត្តិការគ្រោះបន្ទាន់។ គឺជាលំហរូបវន្តដែលតំណាងទីភ្នាក់ងារចម្រុះធ្វើការរួមគ្នា ដើម្បីធ្វើសុខដុមនីយកម្ម និងសម្របសម្រួលសកម្មភាពទាំងឡាយរបស់ខ្លួន ក្នុងអំឡុងពេលមានគ្រោះអាសន្នណាមួយកើតឡើង។ ទីភ្នាក់ងារនីមួយៗ ដែលមានតំណាងនៅក្នុង EOC ក៏អាចមានបន្ទប់ប្រតិបត្តិការមួយ សម្រាប់ប្រតិបត្តិការការងារនៅក្នុងទីភ្នាក់ងារផ្ទាល់ខ្លួនផងដែរ (សូមមើលខាងក្រោម) |
| **គ្រោះថ្នាក់** | ការគំរាមកំហែងជាសក្តានុពលណាមួយ ដែលអាចនឹងកើតឡើងចំពោះសុខភាព និង/ឬសុវត្ថិភាពសាធារណៈ |
| IHR | ច្បាប់និយត្តិកម្មសុខភាពអន្តរជាតិ (2005) |
| IM | ការគ្រប់គ្រងឧប្បត្តិហេតុ |
| IMT | ក្រុមគ្រប់គ្រងឧប្បត្តិហេតុ |
| IMS | ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ |
| MoH | ក្រសួងសុខាភិបាល |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| PHE | គ្រោះអាសន្នសុខភាពសធារណៈ។ ការគំរាមកំហែងណាមួយចំពោះសុខភាព និងសុវត្ថិភាពសាធារណៈ ដែលវិស័យសុខាភិបាលត្រូវបានប្រគល់សិទ្ធិអំណាច ភាពជាអ្នកដឹកនាំ និងការដឹកនាំទូទៅ។ ការគំរាមកំហែងនេះអាចទាក់ទងនឹងសុខភាពទាំងស្រុង (ការផ្ទុះឡើងនូវជំងឺឆ្លង) ឬជាផ្នែកមួយនៃព្រឹត្តិការណ៍ធំ (ការផ្ទុះឡើងនូវជំងឺក្នុងអំឡុងពេលនៃគ្រោះមហន្តរាយធម្មជាតិ) |
| Sitrep | របាយការណ៍ស្ថានភាព |
| SOP | នីតិវិធីប្រតិបត្តិ។ ការកំណត់ច្បាស់អំពីសកម្មភាពនានា ដែលត្រូវអនុវត្តដោយស្ថាប័នទីភ្នាក់ងារ នាយកដ្ឋាន និងកម្មវិធីជាតិនានា ក្នុងអំឡុងពេលនៃគ្រោះអាសន្ន |
| UNCT | ក្រុមការងារសំរបសំរួល របស់អង្គការសហប្រជាជាតិ |
| WHO | អង្គការសុខភាពពិភពលោក |

# សេចក្តីផ្តើម

មជ្ឈមណ្ឌលប្រតិបត្តិការគ្រោះបន្ទាន់ (EOC) គឺជាទីតាំងរូបវន្តមួយសម្រាប់ការសម្របសម្រួលព័ត៌មាន និងធនធានដើម្បីគាំទ្រដល់ការគ្រប់គ្រងព្រឹត្តិការណ៍សុខភាពសាធារណៈ។ បទពិសោធន៍ និងការស្រាវជ្រាវបានបង្ហាញថា ការអនុវត្តន៍ទាន់ពេលវេលានូវមជ្ឈមណ្ឌលប្រតិបត្តិការគ្រោះបន្ទាន់ ផ្តល់ជាវេទិកាដ៏សំខាន់ចាំបាច់ សម្រាប់ការគ្រប់គ្រងគ្រោះអាសន្នសុខភាពសាធារណៈប្រកបដោយប្រសិទ្ធភាព។

EOC ត្រូវតែជាផ្នែកនៃកម្មវិធីដ៏ទូលំទូលាយមួយនៃការត្រៀមលក្ខណៈ ការធ្វើផែនការ និងការកសាងសមត្ថភាព និងជាសមត្ថភាពស្នូលមួយក្នុងចំណោមសមត្ថភាពស្នូល ដែលមានចែងនៅក្នុងនិយត្តិកម្មសុខភាពអន្តរជាតិ (IHR)។ កម្មវិធីបែបនេះ គួររួមមានធាតុផ្សំដូចខាងក្រោម៖

- បង្ការ និងកាត់បន្ថយគ្រោះថ្នាក់
- លើកកម្ពស់ការត្រៀមលក្ខណៈ ដោយធ្វើផែនការ និងប្រមែប្រមូលធនធានសម្រាប់ការឆ្លើយតប
- បង្កើតសមត្ថភាព និងលទ្ធភាពស្ថាប័ននិងបច្ចេកទេសដែលពាក់ព័ន្ធ (ឧ. មន្ទីរពិសោធន៍ និងក្រុមឆ្លើយតបបន្ទាន់)
- អនុវត្តកម្មវិធីឃ្លាំមើលសុខភាពសាធារណៈ
- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងភស្តុភារ
- លើកកម្ពស់កម្មវិធីសុខភាពបរិស្ថាន
- បើកឱ្យសហគមន៍ចូលរួម។

EOC ផ្តល់ជាទីតាំងសំខាន់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ប៉ុន្តែក៏ជាបណ្តុំនៃក្រុមអ្នកជំនាញមកពីពហុវិស័យ ដែលធ្វើការជាមួយគ្នានៅក្នុងមជ្ឈមណ្ឌលនេះ ដែលនេះជាកត្តាដ៏សំខាន់ចាំបាច់ សម្រាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវព្រឹត្តិការណ៍នានា ដែលអាចនឹងមានផលប៉ះពាល់ទៅលើសុខភាពសាធារណៈ។ ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ (IMS) គឺជារចនាសម្ព័ន្ធដែលប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដើម្បីរៀបចំចងក្រងអ្នកជំនាញដែលបានកំណត់អត្តសញ្ញាណ ទៅជាក្រុមគ្រប់គ្រងឧប្បត្តិហេតុ (IMT) ដែលសមស្របសម្រាប់ព្រឹត្តិការណ៍ជាក់លាក់។ រចនាសម្ព័ន្ធនេះ ផ្តល់នូវយន្តការអនុវត្តច្បាស់លាស់ ដែលអាចព្យាករណ៍ និងពង្រីកបាន សម្រាប់គ្រប់គ្រងទៅលើព្រឹត្តិការណ៍សុខភាពសាធារណៈនានា។

# គោលបំណង និងវត្ថុបំណងនៃឯកសារនេះ

គោលបំណងនៃឯកសារនីតិវិធីប្រតិបត្តិ (SOP) គឺដើម្បីបញ្ជាក់ច្បាស់អំពីតួនាទីរបស់ EOC និង IMS/IMT ដើម្បីពង្រឹងការសម្របសម្រួលប្រព័ន្ធគ្រប់គ្រងគ្រោះអាសន្នផ្នែកសុខភាពសាធារណៈ នៅក្នុងប្រទេសកម្ពុជា។

ឯកសារនេះដាក់ចេញនូវការណែនាំសម្រាប់ការបង្កើត ដំណើរការ និងថែរក្សា EOC និងមុខងាររបស់មជ្ឈមណ្ឌលនេះ ដូចជា ប្រព័ន្ធព័ត៌មាន និងបច្ចេកវិទ្យាប្រាស្រ័យទាក់ទងជាដើម ដើម្បីសម្រេចនូវលទ្ធផលមួយដែលអាចព្យាករណ៍បាន មានបទដ្ឋានត្រឹមត្រូវ និងឆ្លើយតបទៅតាមការចង់បាន នៅក្នុងដំណើរការសង្គ្រោះបន្ទាន់ទូទៅ និងនៅក្នុងប្រតិបត្តិការ

ប្រចាំថ្ងៃ។ SOP នេះ ក៏លម្អិតផងដែរ អំពីតួនាទីនៃមុខងារសំខាន់ៗរបស់ IMS និងផ្តល់ជាក្របខ័ណ្ឌកត់ត្រាមួយ សម្រាប់តាមដានដំណើរវិវឌ្ឍន៍របស់ព្រឹត្តិការណ៍។

វត្ថុបំណងនៃ SOP នេះ រួមមាន៖

- បញ្ជាក់អំពីតួនាទីរបស់អ្នកគ្រប់គ្រង EOC នៅក្នុងការចាត់ចែងកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់ EOC ព្រមទាំងនៅក្នុងអំឡុងពេលរៀបចំបង្កើតឡើង
- បញ្ជាក់ពីតួនាទីរបស់ EOC និង IMS/IMT នៅក្នុងការគ្រប់គ្រងស្ថានភាពអាសន្នផ្នែកសុខភាពសាធារណៈ
- កំណត់នូវលក្ខណៈវិនិច្ឆ័យសម្រាប់ការបង្កើត និងដាក់ឱ្យប្រតិបត្តិការនូវ EOC
- កំណត់អំពីតួនាទី និងទំនួលខុសត្រូវរបស់សមាជិក IMT នីមួយៗ នៅក្នុងអំឡុងពេលរៀបចំបង្កើត និងដាក់ឱ្យដំណើរការនូវ EOC
- ផ្តល់ជាក្របខ័ណ្ឌកត់ត្រា សម្រាប់តាមដានវឌ្ឍនភាពនៃព្រឹត្តិការណ៍។

## វិសាលភាព

ឯកសារ រួមទាំងរចនាសម្ព័ន្ធ និងនីតិវិធីទាំងនេះ ត្រូវបានរចនាឡើងដោយប្រើប្រាស់វិធីសាស្ត្រដែលត្រូវនឹងគ្រប់ស្ថានការណ៍គ្រោះថ្នាក់ និងត្រូវប្រើប្រាស់នៅក្នុងការត្រៀមលក្ខណៈ និងការឆ្លើយតបទៅនឹងព្រឹត្តិការណ៍គ្រប់ប្រភេទ ដែលប៉ះពាល់សុខភាពសាធារណៈនៅគ្រប់កម្រិត។

រចនាសម្ព័ន្ធ IMS ត្រូវបានរចនាឡើងឱ្យមានភាពអាចបត់បែនបាន និងអាចពង្រីកបាន ដើម្បីគេអាចយកទៅប្រើប្រាស់សម្រាប់ទាំងព្រឹត្តិការណ៍តូច និងទាំងព្រឹត្តិការណ៍ធំ ទាំងនៅកម្រិតជាតិ និងទាំងនៅកម្រិតក្រោមជាតិ សម្រាប់ព្រឹត្តិការណ៍សុខភាពសាធារណៈ និងសម្រាប់ព្រឹត្តិការណ៍នានា ដែលអាចនឹងមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល ទៅលើសុខភាពសាធារណៈ ដូចជា គ្រោះមហន្តរាយធម្មជាតិ ជាដើម។ គេអាចបំពាក់ធនធានមនុស្សដោយអន្លើក៏បាន ឬពេញលេញក៏បានទៅក្នុង IMS អាស្រ័យទៅតាមព្រឹត្តិការណ៍ និងវិសាលភាពនៃការឆ្លើយតបដែលត្រូវការចាំបាច់។ ប្រព័ន្ធនេះក៏អាចតម្រូវទៅតាមក្រុមឆ្លើយតបនៅកម្រិតខេត្ត នៅក្នុងស្រុក ព្រមទាំងការឆ្លើយតបទ្រង់ទ្រាយធំ ដូចជា ការដាក់ពង្រាយប្រព័ន្ធនេះនៅថ្នាក់អន្តរជាតិផងដែរ។ ប្រព័ន្ធនេះផ្តល់រចនាសម្ព័ន្ធសម្រាប់ការឆ្លើយតបទៅនឹងគ្រោះថ្នាក់ធម្មតា ដែលកើតជាញឹកញាប់ ព្រមទាំងគ្រោះថ្នាក់ដែលគេមិនធ្លាប់ស្គាល់ និងដែលកំពុងផ្ទុះឡើង។

ការវិនិច្ឆ័យហ្មត់ចត់ត្រូវប្រើប្រាស់នៅក្នុងការសម្រេចចិត្តថា តើគួរអនុវត្តនីតិវិធីដែលមាននៅក្នុងឯកសារនេះ យ៉ាងដូចម្តេចដើម្បីឆ្លើយតបទៅនឹងគ្រោះថ្នាក់ជាក់លាក់នីមួយៗ។ ខណៈដែលគេប្រមូលភស្តុតាងបានកាន់តែច្រើន នីតិវិធីជាក់លាក់ទៅតាមករណីគ្រោះថ្នាក់នីមួយៗ នឹងត្រូវបន្ថែមជាឧបសម្ព័ន្ធនៃឯកសារនេះ។

## អ្នកប្រើប្រាស់ឯកសារនេះ

ឯកសារនេះ នឹងត្រូវប្រើប្រាស់ដោយគណៈគ្រប់គ្រង EOC និងបុគ្គលិកដែលក្លាយជាសមាជិក IMT ដើម្បីបំពេញមុខងារសំខាន់ៗនៃ IMS មកពីអង្គភាពនានា ក្នុងនោះរួមទាំងនាយកដ្ឋានផ្សេងៗមកពីក្រសួងសុខាភិបាល (MoH) កម្មវិធីជាតិរបស់ក្រសួងសុខាភិបាល ក្រសួង និងរចនាសម្ព័ន្ធរដ្ឋាភិបាល ដែលពាក់ព័ន្ធផ្សេងទៀត ព្រមទាំងដៃគូអភិវឌ្ឍន៍ ដែលអាចផ្តល់ការគាំទ្រនៅក្នុងការគ្រប់គ្រងគ្រោះអាសន្នសុខភាពសាធារណៈ។

EOC ថ្នាក់ជាតិ គឺត្រូវបោះទីតាំងនៅក្នុងរាជធានីភ្នំពេញ ប៉ុន្តែជាគោលដៅ គេក៏ត្រូវបង្កើត EOC ជាច្រើនទៀត នៅថ្នាក់ក្រោមជាតិ ដែលមានរចនាសម្ព័ន្ធ IMS ដូចគ្នា នៅក្នុងបណ្តាខេត្ត 24 ផ្សេងទៀតផងដែរ នៅត្រឹមឆ្នាំ2020។ ទោះបីជាធនធានហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាអាចនឹងមានភាពខុសគ្នា នៅក្នុង EOC ទាំងនេះក្តី ក៏គោលការណ៍នៃប្រតិបត្តិការ និងគោលការណ៍នៃការបង្កើត និងការប្រព្រឹត្តទៅរបស់ IMS នៅតែដូចគ្នាដដែល ដោយគេត្រូវប្រើប្រាស់ការវិនិច្ឆ័យហ្មត់ចត់បំផុត ដើម្បីកំណត់ថា តើត្រូវកែសម្រួលដំណើរការ ឬតួនាទីជាក់លាក់មួយចំនួន យ៉ាងដូចម្តេច សម្រាប់កម្រិតខេត្តសម្រាប់ព្រឹត្តិការណ៍នីមួយៗ។

## ឯកសារគាំទ្រ

SOP នេះ គួរតែពិចារណាផ្ទួបគ្នាជាមួយគោលការណ៍ណែនាំសាកល សម្រាប់ការត្រៀមលក្ខណៈ និងការឆ្លើយតបចំពោះគ្រោះអាសន្ន ភស្តុតាងជាក់លាក់តាមប្រភេទនៃគ្រោះថ្នាក់ និងឯកសារដែលរៀបចំឡើងជាក់លាក់សម្រាប់ប្រទេសកម្ពុជាស្របតាមបរិបទកម្ពុជា ក្នុងនោះរាប់ទាំងSOP ដែលជាក់លាក់ទៅតាមសេណារីយ៉ូ។

ឧបសម្ព័ន្ធ ១ គឺជាបញ្ជីរាយឈ្មោះឯកសារគាំទ្រនានា និងរបៀបស្វែងរកឯកសារទាំងនោះ។

## សមាសធាតុសំខាន់ៗរបស់ EOC

EOC គឺបានមកពីការផ្តុំចូលគ្នានូវបន្ទប់ដែលបំពាក់បរិក្ខារពិសេស និងប្រព័ន្ធព័ត៌មាន ដែលចាត់ចែង និងគ្រប់គ្រងដោយបុគ្គលិកប្រតិបត្តិការ EOC។ មជ្ឈមណ្ឌលនេះ គាំទ្រដល់ការតាមដាន និងការវាយតម្លៃ ព្រមទាំងការឆ្លើយតបទៅនឹងព្រឹត្តិការណ៍សុខភាពសាធារណៈ និងជួយសម្រួលដល់ការសម្របសម្រួលក្នុងស្រុក និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍សុខភាពសាធារណៈ គ្រោះអាសន្ន និងប្រតិបត្តិការប្រចាំថ្ងៃ។

- **ផែនការ និងនីតិវិធី ៖** EOC ផ្តល់កន្លែងធ្វើការងារ ប៉ុន្តែ គឺជាការសម្របសម្រួលតាមរយៈការអនុវត្តប្រព័ន្ធ IMS និងការដាក់ឱ្យដំណើរការនូវ SOPs ពាក់ព័ន្ធ ដែលនាំឆ្ពោះទៅរកការគ្រប់គ្រង និងការឆ្លើយតបឧប្បត្តិហេតុប្រកបដោយប្រសិទ្ធភាព។
- **ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៖** បរិក្ខាររបស់ EOC គឺជាលំហសម្រាប់ពហុមុខងារ ដែលរួមមាន ទីកន្លែងធ្វើការ ទីកន្លែងប្រជុំ និងសមត្ថភាពបង្ហាញ និងទូរគមនាគមន៍ទំនើប។

- **ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ៖** ដំណោះស្រាយបច្ចេកវិទ្យារបស់ EOC រួមបញ្ចូលគ្នាទាំងប្រព័ន្ធផ្នែករឹង (hardware) និងផ្នែកទន់ (software) ទូរគមនាគមន៍ថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងសាកលលោក ព្រមទាំងគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រង និងចែករំលែកព័ត៌មាន។
- **ប្រព័ន្ធព័ត៌មាន និងទិន្នន័យ ៖** ការគ្រប់គ្រងការឆ្លើយតបគ្រោះអាសន្ន និងប្រតិបត្តិការស្តារឡើងវិញ ពាក់ព័ន្ធនឹងការគ្រប់គ្រងឧប្បត្តិហេតុដែលជាក់លាក់ទៅតាមព្រឹត្តិការណ៍ និងទិន្នន័យជាបរិបទ។ ព័ត៌មានទាំងអស់ចាំបាច់ត្រូវតែគ្រប់គ្រង និងចែករំលែក ក្នុងលក្ខណៈមួយដែលមានការសម្របសម្រួលគ្នាបានល្អ ដើម្បីឱ្យទាំងអ្នកប្រើប្រាស់ EOC និងទាំងអ្នកឆ្លើយតបនៅនឹងកន្លែងព្រឹត្តិការណ៍ អាចចូលប្រើប្រាស់បាន។ IMT និង EOC ផ្តល់លទ្ធភាពចូលប្រើប្រាស់ទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធ ក្នុងលក្ខណៈមួយទាន់ពេលវេលា។
- **ធនធានមនុស្ស ៖** បុគ្គលិកដែលមានសមត្ថភាព និងមានការបណ្តុះបណ្តាលត្រឹមត្រូវ គឺជាកត្តាដ៏សំខាន់ចាំបាច់ក្នុងការសម្រេចបាននូវវត្ថុបំណង និងមុខងាររបស់ EOC។ ធនធានមនុស្សសម្រាប់ការថែទាំ និងដំណើរការ EOC រួមបញ្ចូលទាំងបុគ្គលិកធម្មតា និងបុគ្គលិកបន្ថែមនៅពេលប្រតិបត្តិការត្រូវពង្រីក។

## EOC នៅក្នុងប្រទេសកម្ពុជា

**អាស័យដ្ឋាន (ផែនទី នៅក្នុងរូបភាពទី១) ៖**

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង (CDC) ក្រសួងសុខាភិបាលកម្ពុជា
ដីឡូត៍លេខ ៨០, ផ្លូវ សម្តេចប៉ែននុត (ផ្លូវ ២៨៩) រាជធានីភ្នំពេញ។

**លេខទំនាក់ទំនង ៖**

**ទូរសព្ទ ៖ ០១២ ៨២៥ ៤២៤** (វេជ្ជបណ្ឌិត លី ស្វាន់ ប្រធាន CDC)
**០១២ ៧៣៨ ៣៩៤** (លោក សុខ សំណាង អនុប្រធាន CDC)

**អ៊ីមែល ៖** cdcmoh@gmail.com

**គេហទំព័រ ៖** http://www.cdcmoh.gov.kh/

**រូបភាពទី១៖ ផែនទីទីតាំង EOC នៅកម្ពុជា**



**ទ្រព្យសំខាន់ៗនៅក្នុង EOC នៅក្នុងប្រទេសកម្ពុជា៖**

- ផ្ទាំងបញ្ចាំងបទបង្ហាញខ្នាតធំ (អេក្រង់ LED ទំហំ ៦០" ចំនួន ២) និងអេក្រង់ LCD
- Route computer output សម្រាប់ប្រើជាមួយអេក្រង់បញ្ចាំងបទបង្ហាញខ្នាតធំ
- Webcam ដែលមានគុណភាពរូបភាពខ្ពស់ (មានសមត្ថភាពសម្រាប់ធ្វើ video conference បាន)
- ឧបករណ៍ថតសំឡេង និងឧបករណ៍បំពងសំឡេងចល័ត (ដែលមានសមត្ថភាពធ្វើ audio conference បាន)
- ឧបករណ៍បំពងសំឡេងប្រើ Bluetooth
- ក្តារខៀន និងហ្វឺត
- តុប្រជុំ និងកៅអី
- ម៉ាស៊ីនត្រជាក់
- អ៊ិនធឺណិតល្បឿនលឿន
- កុំព្យូទ័រយួរដៃ និងកុំព្យូទ័រដាក់លើតុ
- កាមេរ៉ា វីដេអូ និងជើង
- LCD projector និង slide
- អាគុយបម្រុង ១២០,000 mAh

**រូបថត ទី១៖ EOC នៅកម្ពុជា**



## ការគ្រប់គ្រងបន្ទប់ EOC

នៅក្រោមការមើលខុសត្រូវរបស់ប្រធាន CDC ក្នុងអំឡុងពេលសកម្មភាពធម្មតាប្រចាំថ្ងៃ និងនៅក្រោមការមើលខុសត្រូវរបស់អ្នកគ្រប់គ្រងឧប្បត្តិហេតុ (IM) ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍អ្វីមួយ អ្នកគ្រប់គ្រង EOC គឺជាសមាជិកបុគ្គលិក CDC ដែលធានាការប្រព្រឹត្តទៅដោយរលូនរបស់ EOC ក្នុងអំឡុងពេលការងារធម្មតា សកម្មភាពត្រៀមលក្ខណៈ និងការរៀបចំ និងក្នុងអំឡុងពេលនៃគ្រោះអាសន្ន ផងដែរ។

សកម្មភាពសំខាន់ៗរបស់អ្នកគ្រប់គ្រង EOC និងភាពញឹកញាប់នៃការអនុវត្តសកម្មភាពទាំងនេះ ក្នុងអំឡុងពេលនៃបរិបទធម្មតា ឬបរិបទគ្រាអាសន្ន ត្រូវបានពិពណ៌នានៅក្នុងតារាង ១។

**តារាងទី ១៖ សកម្មភាពសំខាន់ៗរបស់អ្នកគ្រប់គ្រង EOC**

| សកម្មភាព | ធម្មតា | ក្នុងពេលមានអាសន្ន |
|---|---|---|
| ពិនិត្យឡើងវិញ និងធានាថា SOP ដែលធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុត ត្រូវបានចែកចាយដល់គ្រប់សមាជិក IMT ដែលពាក់ព័ន្ធ ហើយសំណៅជាក្រដាស ត្រូវបានរក្សាទុកនៅក្នុង EOC និងថា ការកែប្រែណាមួយ ឬការលើកលែងណាមួយទៅលើ SOP នេះ ត្រូវបានផ្សព្វផ្សាយទៅដល់អ្នកពាក់ព័ន្ធទាំងអស់ | ប្រចាំខែ | ទៅតាមការចាំបាច់ |
| ធ្វើតេស្តប្រព័ន្ធភ្លើង ប្រព័ន្ធ IT និងសារគមនាគមន៍ទាំងអស់ ដើម្បីធានាថា ប្រព័ន្ធទាំងនេះដំណើរការប្រកបដោយប្រសិទ្ធផល ក្នុងនោះរាប់ទាំងខ្សែទូរស័ព្ទ/ទូរសារ និងការតភ្ជាប់បណ្តាញអ៊ិនធឺណិត | រៀងរាល់ ២ សប្តាហ៍ម្តង | រៀងរាល់ថ្ងៃ |
| ធ្វើការជាមួយបុគ្គលិកគាំទ្រ និងសមាជិក IMT ដើម្បីជានាថា ការបង្ហាញទិន្នន័យត្រូវបានធ្វើបច្ចុប្បន្នភាពត្រឹមត្រូវ និងអាចប្រើប្រាស់បាន នៅមុនកិច្ចប្រជុំនានា | តាមការចាំបាច់ | រៀងរាល់ថ្ងៃ |
| រក្សាទំនាក់ទំនងការងារជិតស្និទ្ធជាមួយអង្គភាពរដ្ឋបាល និងអង្គភាពគាំទ្រទាំងអស់នៅក្នុង MoH ព្រមទាំងក្រសួង និងដៃគូគាំទ្រពីខាងក្រៅផងដែរ | ជាប្រចាំ | ជាប្រចាំ |
| ស្វែងរកការផ្គត់ផ្គង់/ឧបករណ៍ និងចាត់តាំងបុគ្គលិកគាំទ្រ (លេខាអ្នកបច្ចេកទេស) ឱ្យជួយដល់សមាជិករបស់ IMT លើកិច្ចការ ដូចតទៅ៖<br>- ធ្វើការតាមដានប្រព័ន្ធ ដើម្បីពិនិត្យមើលទៅលើការធ្វើដំណើរ និងចលនារបស់បុគ្គលិក ការជ្រើសរើសបុគ្គលិក ការផ្គត់ផ្គង់ និងលទ្ធកម្ម ព្រមទាំងហិរញ្ញវត្ថុ<br>- ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដូចជា បណ្ណុំទិន្នន័យអេឡិចត្រូនិក អេក្រង់បង្ហាញ ការរៀបចំទុកដាក់ឯកសារ ការចែកផ្សព្វផ្សាយឯកសារ ការថតចម្លង និងស្កេន បណ្ណុំព័ត៌មាន បណ្ណាល័យឯកសារយោង ការបង្ហោះ ឯកសារនានាទៅក្នុងគេហទំព័រ។ល។ | ប្រចាំខែ | រៀងរាល់ថ្ងៃ |

## EOC នៅក្នុងគ្រប់គ្រងគ្រាអាសន្ន

មុខងារចម្បងរបស់ EOC នៅក្នុងអំឡុងនៃគ្រាអាសន្នធំៗ រួមមានៈ

- ផ្តល់ទីតាំងកណ្តាលដែលអនុញ្ញាតឱ្យ IMT អាចធ្វើការប្រជុំគ្នា និងសម្របសម្រួលការងារបាន
- ផ្តល់ទីកន្លែងធ្វើការសម្រាប់អ្នកដឹកនាំ និងក្រុមគ្រប់គ្រងមុខងារនីមួយៗរបស់ IMS
- ជួយសម្រួលដល់ការទទួល ការប្រមូល ការប្រៀបធៀប ការបង្ហាញ ការវិភាគ និងការរក្សាទុកទិន្នន័យជាបរិបទ និងព័ត៌មានប្រតិបត្តិការអំពីឧប្បត្តិហេតុ
- គាំទ្រការប្រាស្រ័យទាក់ទង និងការសម្របសម្រួលរវាង EOC និងដៃគូ បណ្តាញ និងអ្នកជំនាញពីខាងក្នុង និងពីខាងក្រៅ
- កំណត់រក និងតាមដានធនធានសម្រាប់គាំទ្រដល់ដំណើរការនៃប្រតិបត្តិការ ក្នុងនោះរាប់បញ្ចូលទាំងសមត្ថភាពពង្រីក សេវា និងសម្ភារៈនានា ដើម្បីគាំទ្រដល់មុខងារ EOC ទាំងអស់។

## ការដាក់ឱ្យដំណើរការ EOC

ដោយផ្អែកលើវិសាលភាព និងភាពស្មុគស្មាញនៃស្ថានភាពអាសន្នដែលអាចនឹងបង្កផលវិបាកផ្នែកសុខភាពសាធារណៈ និងផលវិបាកមនុស្សធម៌ EOC នឹងត្រូវដាក់ឱ្យដំណើរការ នៅកម្រិតខុសៗគ្នា ទៅតាមការចាំបាច់ ដើម្បីបំពេញតម្រូវការនៃសកម្មភាពឆ្លើយតបគ្រោះអាសន្ន របស់ IMT។

កម្រិតសមស្របនៃការដាក់ឱ្យដំណើរការ EOC កម្រិតបុគ្គលិកដែលត្រូវការចាំបាច់ និងពេលវេលាដែលចាំបាច់ ដើម្បីគ្រប់គ្រងព្រឹត្តិការណ៍ ឬគ្រោះអាសន្នមួយ ត្រូវបានកំណត់ដោយអ្នកគ្រប់គ្រងឧប្បត្តិហេតុ ដោយពិគ្រោះយោបល់ជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់មកពីបណ្តាក្រសួងផ្សេងៗទៀត ដៃគូ និងអ្នកពាក់ព័ន្ធសំខាន់ៗ។

តារាង ២ បង្ហាញពីការដាក់ឱ្យដំណើរការ (activation) ៣ កម្រិត និងកម្រិតសមស្របនៃ EOC និងសកម្មភាព IMS ដែលស្របគ្នាទៅនឹងកម្រិតនីមួយៗនៃការដាក់ឱ្យដំណើរការ។

តារាងទី ២៖ កម្រិតដាក់ឱ្យដំណើរការ EOC

| កម្រិត ១ | កម្រិត ២ | កម្រិត ៣ |
|---|---|---|
| IMT និងអ្នកគ្រប់គ្រង EOC ស្ថិតក្នុងស្ថានភាពត្រៀមលក្ខណៈរួចរាល់គ្រប់ពេល ដែលត្រៀមខ្លួនដើម្បីគាំទ្រដល់ការពង្រីកសកម្មភាពទៅតាមការចាំបាច់។ IMT តាមដានជិតដល់ទៅលើការវិវឌ្ឍនៃព្រឹត្តិការណ៍ ធ្វើការវាយតម្លៃការគាំទ្រប្រតិបត្តិការ និងការវាយតម្លៃហានិភ័យ និងធ្វើការវិភាគជាបន្តបន្ទាប់ ទៅលើប្រព័ន្ធប្រកាសអាសន្ន។ | ការដាក់ឱ្យដំណើរការដោយអន្លើដែលនឹងតម្រូវឱ្យមានការពង្រីកម៉ោង។ ផ្នែកប្រតិបត្តិការមុខងាររបស់ IMS ត្រូវបានដាក់ឱ្យដំណើរការ នៅក្នុង EOC ប៉ុន្តែអាស្រ័យទៅតាមព្រឹត្តិការណ៍ វាអាចទៅរួចដែលថា មិនមែនមុខងារសំខាន់ៗទាំងអស់ នឹងត្រូវដាក់ឱ្យដំណើរការនោះទេ ហើយមុខងារជាច្រើនអាចនឹងស្ថិតនៅក្នុងស្ថានភាពត្រៀម។ | ការដាក់ឱ្យដំណើរការក្នុងកម្រិតពេញលេញ ជាមួយនឹងម៉ោងការងារបន្តជាប់រហូត (24 ម៉ោងក្នុងមួយថ្ងៃ) ការដាក់ឱ្យ IMS ដំណើរការពេញលេញ និងបុគ្គលិកបន្ថែម ក៏អាចនឹងត្រូវការជាចាំបាច់ផងដែរ។ |

ការដាក់ឱ្យដំណើរការ EOC ត្រូវបានប្រាស្រ័យទាក់ទងទៅកាន់គ្រប់មុខងាររបស់ IMS ព្រមទាំងនាយកដ្ឋាន ក្រសួងស្ថាប័ន និងដៃគូសុខាភិបាលពាក់ព័ន្ធដទៃទៀត ដោយប្រើប្រាស់បញ្ជីទំនាក់ទំនងជាក់លាក់ទៅតាមប្រភេទគ្រោះថ្នាក់ នៅក្នុងឧបសម្ព័ន្ធ ២។

## អ្វីដែលអាចកើតឡើង នៅពេលនៃការដាក់ឱ្យដំណើរការ

មានកត្តាមួយចំនួនដែលជះឥទ្ធិពលនៅពេល EOC ត្រូវបានដាក់ឱ្យដំណើរការ និងស្ថិតនៅកម្រិតណាមួយ។ កត្តាដែលអាចកើតឡើងនៅពេលដាក់ឱ្យដំណើរការ ត្រូវបានរៀបរាប់នៅខាងក្រោម ប៉ុន្តែ គេត្រូវប្រើប្រាស់ការវិនិច្ឆ័យឱ្យបានហ្មត់ចត់បំផុតនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

កម្រិតនៃការដាក់ឱ្យដំណើរការ EOC មិនមែនថេរទេ គឺវាអាចកើន ឬថយ ខណៈដែលព្រឹត្តិការណ៍វិវឌ្ឍន៍។ ខណៈដែលគេទទួលបានព័ត៌មានថ្មីៗ និងធ្វើការវាយតម្លៃហានិភ័យជាហូរហែ ការផ្លាស់ប្តូរធនធានមនុស្ស និងធនធានដទៃទៀត ព្រមទាំងការប្រែប្រួលបរិបទ ដូចជា ភាពរសើបផ្នែកនយោបាយ ពាក្យចចាមអារ៉ាម និងស្ថានភាពសន្តិសុខដែលប្រែប្រួល នោះកម្រិតនៃការដាក់ឱ្យដំណើរការគួរត្រូវបានពិនិត្យឡើងវិញ និងធ្វើការផ្លាស់ប្តូរទៅតាមអ្វីដែលសមស្រប។

នៅពេលណាដែលមានការផ្លាស់ប្តូរស្ថានភាពនៃការដាក់ឱ្យដំណើរការ ត្រូវតែប្រាស្រ័យទាក់ទងព័ត៌មានអំពីការផ្លាស់ប្តូរនេះទៅគ្រប់មុខងាររបស់ IMS ដោយលម្អិតអំពីការផ្លាស់ប្តូរនៃសកម្មភាពដែលគេរំពឹងចង់បាន ដែលនឹងកើន ឬថយ។

ប្រសិនបើមិនច្បាស់ អ្វីដែលល្អបំផុត គឺត្រូវរៀបចំឱ្យបានលើស និងឆ្លើយតបឱ្យបានលើស ជាមួយនឹងកម្រិតនៃការដាក់ឱ្យដំណើរការ EOC ខ្ពស់លើស ដើម្បីជានានូវការឆ្លើយតបដែលសមស្រប។ ប្រការនេះអាចពិនិត្យឡើងវិញ និងកាត់បន្ថយ ប្រសិនបើព័ត៌មានថ្មីបង្ហាញថា ការដាក់ឱ្យដំណើរការត្រឹមកម្រិតទាបជាការគ្រប់គ្រាន់ហើយនោះ។

តារាង ៣ បង្ហាញពីកត្តានានា ដែលអាចកើតឡើងសម្រាប់ការដាក់ឱ្យដំណើរការ EOC រួមជាមួយកម្រិតទាក់ទងគ្នាទៅវិញទៅមកនៃការដាក់ឱ្យដំណើរការ EOC។

**តារាងទី ៣៖ កត្តានានាដែលអាចជំរុញការដាក់ឱ្យដំណើរការ** EOC

| កត្តាជំរុញការដាក់ឱ្យដំណើរការ EOC | កម្រិតនៃការដាក់ឱ្យដំណើរការ EOC |
|---|---|
| ប្រព័ន្ធប្រកាសអាសន្ន បង្ហាញពីព្រឹត្តិការណ៍មួយដែលមានផលប៉ះពាល់ដល់សុខភាពសាធារណៈអាចនឹងកើតឡើង | ការដាក់ឱ្យដំណើរការកម្រិត ១ គឺសមស្របជាមួយនឹងការតាមដាន និងការវាយតម្លៃហានិភ័យជាប់ជាប្រចាំ ខណៈដែលព្រឹត្តិការណ៍កើតឡើង ឬវិវឌ្ឍន៍ទៅមុខ។ គេអាចប្រើ EOC ជាវិធានការត្រៀមលក្ខណៈ ដើម្បីចែករំលែកព័ត៌មានជាមួយសមាជិកសក្តានុពលរបស់ IMT។ បន្តតាមដាន និងវាយតម្លៃឡើងវិញទៅលើហានិភ័យ ខណៈដែលទទួលបានព័ត៌មានថ្មីៗ ដើម្បីកំណត់ថាតើគួរបង្កើនកម្រិត ឬបញ្ឈប់ដំណើរការ |
| ព្រឹត្តិការណ៍ទាមទារឱ្យមានសកម្មភាព និង/ឬធនធានមនុស្ស ច្រើនជាងអ្វីដែលចាំបាច់សម្រាប់សកម្មភាពប្រចាំថ្ងៃរបស់ CDC/MoH ទោះបីដោយសារភាពធ្ងន់ធ្ងរក្តី វិសាលភាពក្តី ភាពស្មុគស្មាញក្តី ឬប្រភេទនៃគ្រោះថ្នាក់ក្តី | ការដាក់ឱ្យដំណើរការកម្រិត ២ ឬ ៣ ជាមួយនឹងការដាក់ឱ្យដំណើរការប្រព័ន្ធ IMS ដោយអន្លើ ឬពេញលេញ។ ចូរពិចារណាទៅលើព័ត៌មានជាក់លាក់តាមប្រភេទនៃគ្រោះថ្នាក់ ព្រមទាំងកត្តាបរិបទនានា។ ចូរតាមដានជាបន្តបន្ទាប់ និងវាយតម្លៃឡើងវិញទៅលើហានិភ័យ ខណៈដែលទទួលបានព័ត៌មានថ្មី ដើម្បីកំណត់ថា តើកម្រិតនៃការដាក់ឱ្យដំណើរការ គួរតែបង្កើន ឬបន្ថយ |
| ព្រឹត្តិការណ៍តម្រូវឱ្យមានការឆ្លើយតបដែលមានលក្ខណៈចម្រុះនាយកដ្ឋាន ចម្រុះក្រសួង ចម្រុះវិស័យ | ការដាក់ឱ្យដំណើរការកម្រិត ២ ឬ ៣ ជាមួយនឹងការដាក់ឱ្យដំណើរការប្រព័ន្ធ IMS ដោយអន្លើ ឬពេញលេញ។ ចូរពិចារណាទៅលើព័ត៌មានជាក់លាក់តាមប្រភេទនៃគ្រោះថ្នាក់ ព្រមទាំងកត្តាបរិបទនានា។ ចូរតាមដានជាបន្តបន្ទាប់ និងវាយតម្លៃឡើងវិញទៅលើហានិភ័យ ខណៈដែលទទួលបានព័ត៌មានថ្មី ដើម្បីកំណត់ថា តើកម្រិតនៃការដាក់ឱ្យដំណើរការ គួរតែបង្កើន ឬបន្ថយ |
| ហានិភ័យត្រូវបានវាយតម្លៃ ថាមានកម្រិតខ្ពស់ | ការដាក់ឱ្យដំណើរការកម្រិត ១, ២ ឬ ៣។ ចូរពិចារណាទៅលើព័ត៌មានជាក់លាក់តាមប្រភេទនៃគ្រោះថ្នាក់ ព្រមទាំងកត្តាបរិបទនានា។ ចូរតាមដានជាបន្តបន្ទាប់ និងវាយតម្លៃឡើងវិញទៅលើហានិភ័យ ខណៈដែលទទួលបានព័ត៌មានថ្មី ដើម្បីកំណត់ថា តើកម្រិតនៃការដាក់ឱ្យដំណើរការ គួរតែបង្កើន ឬបន្ថយ |

| | |
|---|---|
| ស្ថានភាពអាសន្នត្រូវបានប្រកាស | ការដាក់ឱ្យដំណើរការកម្រិត ១, ២ ឬ ៣ អាស្រ័យទៅតាមភាពធ្ងន់ធ្ងរ វិសាលភាព ភាពស្មុគស្មាញ និងប្រភេទនៃគ្រោះថ្នាក់។ ការប្រកាសស្ថានភាពអាសន្ន នឹងនាំឱ្យមានការឆ្លើយតបលក្ខណៈពហុវិស័យ និងអាចអមដោយពាក្យចចាមអារ៉ាម ភាពច្របូកច្របល់ និងការភ័យស្លន់ស្លោ ព្រមទាំងភាពរសើបផ្នែកនយោបាយ។ ដូច្នេះ គេគួរតែដាក់ឱ្យដំណើរការកម្រិតខ្ពស់។ ចូរធ្វើការតាមដានជាបន្តបន្ទាប់ និងវាយតម្លៃឡើងវិញទៅលើហានិភ័យ ខណៈដែលទទួលបានព័ត៌មានថ្មី ដើម្បីកំណត់ថាតើគួរបង្កើន ឬបន្ថយកម្រិត |

## សកម្មភាពសំខាន់របស់ EOC បន្ទាប់ពីត្រូវបានដាក់ឱ្យដំណើរការ

បន្ទាប់ពី EOC ត្រូវបានដាក់ឱ្យដំណើរការ សកម្មភាពនានានៅក្នុងតារាង ៤ គួរតែបំពេញឱ្យបានរួចរាល់ទៅតាមគម្រោងពេលវេលាដែលបានស្នើ សមស្របទៅតាមព្រឹត្តិការណ៍នីមួយៗ និងទៅតាមកម្រិតនៃការដាក់ឱ្យដំណើរការ។

**តារាងទី ៤៖ សកម្មភាពសំខាន់របស់ EOC នៅក្រោយការដាក់ឱ្យដំណើរការ**

| គម្រោងពេល | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| បន្ទាន់ | វាយតម្លៃស្ថានភាព និងកំណត់ពីតម្រូវការបុគ្គលិក ដែលចាំបាច់ដើម្បីបំពេញមុខងារសំខាន់ៗរបស់ IMS (ជាក់លាក់ទៅតាមព្រឹត្តិការណ៍ និងកម្រិតនៃការដាក់ឱ្យដំណើរការ) | IM (ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍គ្រោះថ្នាក់) |
| បន្ទាន់ | ជួបប្រជុំគ្នាដើម្បីបញ្ជាក់ពីធនធាន EOC ដែលត្រូវការចាំបាច់សម្រាប់ព្រឹត្តិការណ៍ និងកម្រិតនៃការដាក់ឱ្យដំណើរការ។ បញ្ជាក់អំពីមុខងារនៃឧបករណ៍ដែលចាំបាច់ | IM និងអ្នកគ្រប់គ្រង EOC |
| បន្ទាន់ | កោះហៅប្រជុំលើកដំបូង ជាមួយ IMT នៅក្នុង EOC ដើម្បី៖<br>- បញ្ជាក់ច្បាស់អំពីរចនាសម្ព័ន្ធ IMS ខ្សែរយៈនៃការទទួលខុសត្រូវ ភាពញឹកញាប់នៃកិច្ចប្រជុំ IMT វិធីប្រាស្រ័យទាក់ទងគ្នា លក្ខខណ្ឌតម្រូវសម្រាប់ការតាមដាន ការរក្សាការសម្ងាត់ និងពិធីសារនៃការចែករំលែកទិន្នន័យ<br>- ពន្យល់ប្រាប់ IMT អំពីការប្រើប្រាស់ EOC និងផ្តល់ការគាំទ្រ និងការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់ ស្តីពីបរិក្ខារ ឧបករណ៍ និងប្រព័ន្ធព័ត៌មាន។ ធានាថា IMT ដឹងអំពីកន្លែង និងរបៀបដែលត្រូវប្រើប្រាស់ធនធាន ដែលសំខាន់ចាំបាច់<br>- បញ្ជាក់អំពីបញ្ជីទំនាក់ទំនង និងសេចក្តីលម្អិតនៃបញ្ជីចែកចាយ | IM ត្រូវកោះប្រជុំ៖ អ្នកគ្រប់គ្រង EOC ត្រូវគាំទ្រការជួយសម្រួលដល់កិច្ចប្រជុំនេះ និងអញ្ជើញសមាជិកឱ្យចូលរួម |

| | | |
|---|---|---|
| | - បង្កើតព័ត៌មានទំនាក់ទំនងជាមួយនាយកដ្ឋាន ក្រសួង អង្គការ និងដៃគូដទៃទៀត ដែលអាចនឹងផ្តល់ការគាំទ្រដល់ការឆ្លើយតបទៅនឹងព្រឹត្តិការណ៍<br>- ប្រជុំណែនាំដល់ IMT ស្តីពីព័ត៌មានដែលបានដឹង និងដែលមិនបានដឹង<br>- កំណត់អំពីវត្ថុបំណង និងផែនការបឋមនៃការឆ្លើយតប<br>- ពិភាក្សាអំពីការប្រើប្រាស់ធនធានសម្រាប់ការឆ្លើយតប កំណត់រក (និងដាក់ឱ្យដំណើរការ ប្រសិនបើចាំបាច់) នូវប្រេកនៃការផ្តល់មូលនិធិដែលបានដឹង ឬស្គាល់ និងគម្លាតធនធាន | |
| បន្ទាន់ និងជាបន្តបន្ទាប់ | ការចែករំលែកព័ត៌មានជាបន្តបន្ទាប់នៅក្នុងចំណោមសមាជិក IMT ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មាន ដូចជា ចំនួនករណី ព័ត៌មានភូមិសាស្ត្រ និយមន័យនៃករណី និងលទ្ធផលវាយតម្លៃតម្រូវការ។ ផ្តល់លទ្ធភាពដល់ការបង្ហាញព័ត៌មានបែបនេះ សម្រាប់កិច្ចប្រជុំ IMT នៅក្នុង EOC | IMT; អ្នកគ្រប់គ្រង EOC គាំទ្រដល់ការបង្ហាញព័ត៌មាន |
| បន្ទាន់ និងជាបន្តបន្ទាប់ | ធានាការកត់ត្រា និងតាមដានកិច្ចការនានា ដែលបំពេញដោយមុខងារសំខាន់ សំណើសុំធនធាន និងការដាក់ពង្រាយ ព្រមទាំងចែកចាយព័ត៌មាននេះនៅទូទាំង IMT | IMT; អ្នកគ្រប់គ្រង EOC ជាអ្នកចែកចាយ |
| បន្ទាន់ | កំណត់ និងអនុវត្តវិធីសាស្ត្រនៃការចែករំលែកព័ត៌មានប្រតិបត្តិការ ដូចជាការផលិត និងចែកចាយរបាយការណ៍ស្តីពីស្ថានភាព (របាយការណ៍ស្ថានភាព) ទាំងសម្រាប់ផ្ទៃក្នុង និងទាំងការផ្សព្វផ្សាយទៅខាងក្រៅ | IMT |
| បន្ទាន់ និងជាបន្តបន្ទាប់ | ធ្វើឱ្យប្រាកដថា បញ្ជីព័ត៌មានទំនាក់ទំនងដែលមានបច្ចុប្បន្នភាព ត្រូវបានពិនិត្យ និងចែកផ្សព្វផ្សាយ ស្របទៅតាមការផ្លាស់ប្តូរ IMS នៅក្នុងចំណោមសមាជិកក្រុម | អ្នកគ្រប់គ្រង EOC |
| ពង្រីក | គាំទ្រកិច្ចប្រជុំ IMT ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ ដោយធានាថាឧបករណ៍នានា ដំណើរការបានត្រឹមត្រូវ | អ្នកគ្រប់គ្រង EOC |
| នៅក្រោយព្រឹត្តិការណ៍បានបញ្ចប់ | ការពិនិត្យឡើងវិញក្រោយការអនុវត្តសកម្មភាពរួច នឹងត្រូវធ្វើឡើងនៅក្នុង EOC ជាមួយសមាជិក IMT ទាំងអស់ដែលចូលរួម ក្នុងនោះរាប់ទាំង IM និងអ្នកគ្រប់គ្រង EOC | សមាជិក IMT<br>អ្នកគ្រប់គ្រង EOC |

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

ដើម្បីធានាថាការឆ្លើយតបដែលមានការសម្របសម្រួលបានល្អ និងមានប្រសិទ្ធផលសម្រាប់គ្រោះអាសន្ននានាអាចសម្រេចបានរចនាសម្ព័ន្ធ IMS ដូចនៅក្នុងរូបភាពទី ២ នឹងត្រូវប្រើប្រាស់។ រចនាសម្ព័ន្ធនេះ ត្រូវបានទទួលស្គាល់ជាអន្តរជាតិថា

ជាវិធានអនុវត្តន៍ល្អបំផុតសម្រាប់ការគ្រប់គ្រងគ្រោះអាសន្ន ដូច្នេះវាជួយសម្រួលដល់ការសម្របសម្រួលការងារកាន់តែប្រសើរឡើងថែមទៀត ជាមួយនឹងដៃគូសំខាន់ៗ។

ប្រព័ន្ធ IMS នឹងត្រូវបំពាក់ទៅដោយអ្នកជំនាញការ ដែលសមស្របទៅតាមប្រភេទនៃព្រឹត្តិការណ៍។ ដ្យាក្រាមនៅក្នុងឧបសម្ព័ន្ធ ៣ គួរតែប្រើប្រាស់ដើម្បីផ្តល់បច្ចុប្បន្នភាពដល់សមាជិក IMT រៀងរាល់ពេលដែលមានការផ្លាស់ប្តូរនៅក្នុងមុខងារសំខាន់ៗ ហើយដ្យាក្រាមនេះគួរតែដាក់តាំងបង្ហាញនៅក្នុង EOC។ ឧទាហរណ៍នៃការដាក់តាំងបង្ហាញនេះ មាននៅក្នុងឧបសម្ព័ន្ធ ៤ ដែលបង្ហាញពីរចនាសម្ព័ន្ធ IMS នៅមុនពេលកំណត់អត្តសញ្ញាណ សម្រាប់គ្រោះអាសន្នសុខភាពសាធារណៈ ដូចជា ការផ្ទុះឡើងនៃជំងឺអេបូឡា ជាដើម។ ខណៈដែល IMTs ត្រូវបានកំណត់អត្តសញ្ញាណសម្រាប់ប្រភេទគ្រោះថ្នាក់ខុសៗគ្នា គេនឹងបញ្ចូលវាទៅក្នុងឧបសម្ព័ន្ធ ៤ បន្ថែមទៀត។

បញ្ជីអ្នកជំនាញបច្ចេកទេស ដែលអាចរៀបចំសាថ្មីបានដើម្បីបំពេញតាមតម្រូវការនៃ IMS ត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ២។

### រូបភាពទី ២៖ រចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ




ដើម្បីអនុវត្តការឆ្លើយតបប្រតិបត្តិការដែលមានប្រសិទ្ធភាព IMS មានមុខងារសំខាន់ៗចំនួន ៦ ដែលខ្លួនត្រូវតែបំពេញ (ដូចមានបង្ហាញជាអក្សរពណ៌ក្រហមនៅខាងលើ)។ ខណៈដែលស្ថានភាពអាសន្នមួយវិវឌ្ឍន៍ប្រែប្រួល មុខងារ IMS នឹងត្រូវតែកែសម្រួលឱ្យត្រូវនឹងបរិបទ ចំណែកឯមុខងារបន្ទាប់បន្សំអាចបន្ថែម (ឬដកចេញ) ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលរីក (ឬរួម) សម្រាប់សេវា និងការគាំទ្រ។ យោងទៅតាមកម្រិតនៃការឆ្លើយតប និងលទ្ធភាពរកបានបុគ្គលិក មុខងារច្រើនលើសពីមួយ អាចនឹងត្រូវបំពេញដោយមនុស្សម្នាក់ ឬមនុស្សច្រើននាក់អាចនឹងធ្វើការរួមគ្នាទៅលើមុខងារជាក់លាក់មួយចំនួន។ តួនាទីរបស់មុខងារសំខាន់នីមួយៗ ត្រូវបានលម្អិតនៅក្នុងតារាងពីលេខ ៥ ដល់លេខ ១០ ដូចខាងក្រោម៖

**តារាងទី ៥៖ តួនាទីនៃមុខងារដឹកនាំសំខាន់ៗ**

| មុខងារសំខាន់ | បរិយាយអំពីតួនាទី |
|---|---|
| **ថ្នាក់ដឹកនាំ**<br>មុខងារថ្នាក់ដឹកនាំ ទទួលខុសត្រូវលើការគ្រប់គ្រងទូទៅ នៃការឆ្លើយតប ក្នុងនោះរាប់ទាំងការមើលខុសត្រូវលើប្រធានក្រុមនៃមុខងារ IMS ដទៃទៀតផងដែរ។ មុខងារនេះរួមមាន អនុមុខងារសំខាន់ៗចំនួន ៥៖ | **ថ្នាក់ដឹកនាំ៖** ទទួលខុសត្រូវលើការដឹកនាំជាយុទ្ធសាស្ត្រ និងការមើលខុសត្រូវ និងគ្រប់គ្រងប្រចាំថ្ងៃ នៃការឆ្លើយតបគ្រោះអាសន្ន។ អ្នកគ្រប់គ្រងឧប្បត្តិហេតុ ធ្វើការជាមួយនាយកដ្ឋានក្រសួងស្ថាប័ន និងដៃគូសុខាភិបាលសំខាន់ៗ ដើម្បីព្រមព្រៀងគ្នាទៅលើអាទិភាព និងវត្ថុបំណង សម្រាប់ការឆ្លើយតបផ្នែកសុខាភិបាល ដែលអនុលោមពេញលេញទៅតាមគោលការណ៍មនុស្សធម៌។ មុខងារថ្នាក់ដឹកនាំចម្បង ត្រូវបានប្រគល់ទៅឱ្យអ្នកគ្រប់គ្រងឧប្បត្តិហេតុ ដែលធ្វើការជិតស្និទ្ធជាមួយអ្នកជំនាញបច្ចេកទេស នៅក្នុងការកំណត់អាទិភាពនៃការឆ្លើយតប រៀបចំយុទ្ធសាស្ត្រឆ្លើយតប និងបញ្ជាក់អំពីអន្តរាគមន៍ប្រយុទ្ធប្រឆាំងជំងឺដែលសំខាន់ចាំបាច់។ |
| | **សុខភាព សុខុមាលភាព និងសន្តិសុខរបស់បុគ្គលិក៖** ទទួលខុសត្រូវចំពោះការតាមដានរាល់បញ្ហាសន្តិសុខ និងចាត់វិធានការជាក់ស្តែង ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់បុគ្គលិក IMS ទាំងអស់។ |
| | **ការប្រាស្រ័យទាក់ទង៖** ទទួលខុសត្រូវលើការសម្របសម្រួលការឆ្លើយតបរបស់ក្រសួងទៅកាន់សារព័ត៌មាន និងការសាកសួរព័ត៌មានពីសំណាក់សាធារណៈជន ព្រមទាំងការផលិត និងផ្សព្វផ្សាយឯកសារប្រាស្រ័យទាក់ទងសម្រាប់ទាំងផ្ទៃក្នុង និងការផ្សព្វផ្សាយទៅក្រៅ។ ប្រើប្រាស់យុទ្ធសាស្ត្រសកម្មមុន ដើម្បីឱ្យការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងវិបត្តិមានភាពស៊ីសង្វាក់គ្នា និងទាក់ទងគ្នា។ |
| | **ទំនាក់ទំនងខាងក្រៅ៖** ទទួលខុសត្រូវលើការសម្របសម្រួលរាល់សកម្មភាពដែលទាក់ទងនឹងការកៀងគរធនធាន ទំនាក់ទំនងជាមួយម្ចាស់ជំនួយ និងការតស៊ូមតិ ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិ និងផែនការសកម្មភាពរបស់ IMS។ |
| | **ការគ្រប់គ្រង EOC៖** អ្នកគ្រប់គ្រង EOC ធានាថា ប្រព័ន្ធទាំងអស់របស់មជ្ឈមណ្ឌល ( ទាំងផ្នែករឹង និងទាំងផ្នែកទន់ ) ព្រមទាំងឧបករណ៍គាំទ្រដល់បុគ្គលិក ត្រូវបានថែរក្សា និងមានដំណើរការត្រឹមត្រូវល្អ នៅពេលត្រូវការជាចាំបាច់។ |

**តារាងទី ៦៖ តួនាទីនៃមុខងារសម្របសម្រួលដៃគូ**

| មុខងារសំខាន់ | បរិយាយអំពីតួនាទី |
|---|---|
| **សម្របសម្រួលដៃគូ**<br>មុខងារនេះធ្វើការដើម្បីលើកកម្ពស់ភាពស៊ីសង្វាក់គ្នានៃកិច្ចប្រឹងប្រែងឆ្លើយតបព័ត៌មាន និងធនធាននៅក្នុងចំណោមនាយកដ្ឋាន ក្រសួងស្ថាប័ន ដៃគូ ព្រមទាំងស្ថាប័នតំបន់ និងពិភពលោក។ មុខងារនេះមានអនុមុខងារចំនួន ២៖ | **ការសម្របសម្រួលវិស័យសុខាភិបាល និងអន្តរវិស័យ៖** ទទួលខុសត្រូវធានាថាសកម្មភាពរួមគ្នាសម្រេចបានលទ្ធផលជាការគ្របដណ្តប់ និងសេវាសុខភាពដែលមានគុណភាពសមស្រប សម្រាប់ប្រជាជនដែលរងផលប៉ះពាល់ ជាពិសេស អ្នកដែលងាយរងគ្រោះបំផុត។ គោលបំណង គឺដើម្បីបើកឱ្យអ្នកពាក់ព័ន្ធចូលរួមនៅក្នុងការវាយតម្លៃហានិភ័យ និងការវាយតម្លៃតម្រូវការ ការធ្វើផែនការ ការគ្រប់គ្រង និងចែករំលែកព័ត៌មាន ការផ្តល់សេវា ការតាមដាន ការធានាគុណភាព និងការតស៊ូមតិ។ |
| | **ទំនាក់ទំនង៖** ទទួលខុសត្រូវលើការឆ្លើយតបទៅនឹងសំណើរមកពីក្រុមអ្នកពាក់ព័ន្ធទាំងនៅក្នុង និងមិនមែននៅក្នុងវិស័យសុខាភិបាល។ មន្ត្រីទំនាក់ទំនងប្រមូលបញ្ហា និងការបារម្ភនានា ដែលទាក់ទងនឹងបញ្ហាអន្តរអង្គការ ដាក់ជូនទៅអ្នកគ្រប់គ្រងឧប្បត្តិហេតុ រួមជាមួយនឹងអនុសាសន៍សម្រាប់វិធានការដែលត្រូវអនុវត្ត។ |

**តារាងទី ៧៖ តួនាទីនៃមុខងារព័ត៌មាន និងផែនការ**

| មុខងារសំខាន់ | បរិយាយអំពីតួនាទី |
|---|---|
| **ព័ត៌មាន និងផែនការ**<br>មុខងារនេះប្រមូល វិភាគ និងផ្សព្វផ្សាយព័ត៌មានស្តីពីហានិភ័យសុខភាព តម្រូវការ ការគ្របដណ្តប់សេវា និងការខ្វះចន្លោះ ព្រមទាំងលទ្ធផលនៃការឆ្លើយតប។ មុខងារនេះប្រើប្រាស់ព័ត៌មានដើម្បីរៀបចំបង្កើត និងកែលម្អការឆ្លើយតប ព្រមទាំងផ្តល់ជាមូលដ្ឋានសម្រាប់ការធ្វើផែនការស្តារ។ មុខងារនេះមានអនុមុខងារមួយចំនួនទៀតផងដែរ។ | **ព័ត៌មាន៖** ទទួលខុសត្រូវក្នុងការប្រមូល ប្រៀបធៀប វិភាគ និងផ្សព្វផ្សាយទិន្នន័យដែលដាក់លាក់ទៅតាមស្ថានភាពអាសន្ន ព័ត៌មានគ្រប់គ្រងគ្រោះអាសន្ន និងទិន្នន័យបរិបទ។ មុខងារនេះរួមមានអនុមុខងារដូចខាងក្រោម៖<br>- **ការវាយតម្លៃហានិភ័យ និងតម្រូវការ៖** ការវាយតម្លៃហានិភ័យជាបន្តបន្ទាប់អនុញ្ញាតឱ្យអ្នកពាក់ព័ន្ធអាចធ្វើសេចក្តីសម្រេចចិត្តបានហ្មត់ចត់ អំពីការទប់ស្កាត់ ឬការកាត់បន្ថយផលប៉ះពាល់នៃគ្រោះអាសន្នមួយ។ ការវាយតម្លៃតម្រូវការ គឺជាដំណើរការជាលក្ខណៈប្រព័ន្ធ ដែលកំណត់អំពីផលប៉ះពាល់សុខភាពទូទៅ និងផលវិបាកលើសុខភាពនៃគ្រោះអាសន្ន លទ្ធភាពប្រព្រឹត្តទៅ និងសមិទ្ធកម្មនៃសេវាសុខភាព និងកំណត់រកមើលភាពខ្វះចន្លោះនៅក្នុងសមត្ថភាព និងប្រតិបត្តិការ សម្រាប់គោលបំណងនៃកំណត់អាទិភាព និងការអនុវត្តការឆ្លើយតប។<br>- **ការឱ្យដឹងមុន និងការឃ្លាំមើល៖** អនុមុខងារនេះពង្រឹងការប្រមូល ការវិភាគ និងការប្រាស្រ័យទាក់ទងជាលក្ខណៈប្រព័ន្ធ នូវព័ត៌មាននានា ដែលត្រូវប្រើប្រាស់ដើម្បីរកមើល ផ្ទៀងផ្ទាត់ និងស៊ើបអង្កេតព្រឹត្តិការណ៍ និងហានិភ័យសុខភាពនានា។ អនុមុខងារនេះ ក៏គាំទ្រដល់ការផ្សព្វផ្សាយទិន្នន័យដែលទាក់ទងនឹងព្រឹត្តិការណ៍សុខភាពសាធារណៈផងដែរ។ ដោយសហការជាមួយក្រុមប្រតិបត្តិសុខភាព និងក្រុមជំនាញបច្ចេកទេស អនុមុខងារនេះបង្កើត ពង្រឹង និងដំណើរ |

| | |
|---|---|
| | ការ នូវក្រុមឆ្លើយតបបន្ទាន់ ដែលទទួលខុសត្រូវលើការស៊ើបអង្កេតហ័សទៅលើតម្រុយព័ត៌មាន ការវាយតម្លៃហានិភ័យនៅតាមមូលដ្ឋាន និងការឆ្លើយតបប្រតិបត្តិទាន់ពេលវេលា។<br>- **ការតាមដាន និងវាយតម្លៃ ៖** អនុមុខងារនេះតាមដានជាលក្ខណៈប្រព័ន្ធទៅលើការវិវឌ្ឍនៃគ្រោះអាសន្ន និងវឌ្ឍនភាពនៃការឆ្លើយតប នៅក្នុងការសម្រេចបានទៅតាមវត្ថុបំណងនៃផែនការឆ្លើយតបប្រតិបត្តិ ។ អនុមុខងារនេះ ពាក់ព័ន្ធទៅនឹងការកំណត់សូចនាករត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងប្រភពព័ត៌មាន ការបង្កើតទិសដៅប្រតិបត្តិ ការប្រមូល និងបកស្រាយទិន្នន័យ និងការតាមដានវឌ្ឍនភាព ដើម្បីកំណត់ថាតើការឆ្លើយតបសម្រេចបានទៅតាមវត្ថុបំណងរបស់ខ្លួន ដែរ ឬទេ។ ប្រសិនបើការឆ្លើយតបមិនស្ថិតនៅលើផ្លូវត្រឹមត្រូវទេ បុគ្គលិកដែលទទួលខុសត្រូវលើអនុមុខងារនេះ ត្រូវធ្វើវិភាគរកមូលហេតុ និងផ្តល់អនុសាសន៍ស្តីពីវិធានការកែប្រែ និង/ឬការផ្លាស់ប្តូរទិសដៅ ដោយសហការណ៍ជាមួយដៃគូ និងផ្នែកទទួលខុសត្រូវដទៃទៀត។<br>- **ផលិតផលព័ត៌មាន និងការផ្សព្វផ្សាយ៖** អនុមុខងារនេះចងក្រងព័ត៌មានពីប្រភពនានា ដូចជា ការវាយតម្លៃហានិភ័យ/តម្រូវការ ប្រព័ន្ធឱ្យដឹងមុន និងប្រព័ន្ធឃ្លាំមើល ប្រព័ន្ធតាមដានការឆ្លើយតប (ឧ. ការគ្របដណ្តប់នៃសេវា) និងការស្ទង់មតិនានា ដើម្បីបង្កើតផលិតផលព័ត៌មាន ដែលអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធទាំងឡាយអាចតាមដានហានិភ័យ និងតម្រូវការផ្នែកសុខភាពសាធារណៈ ដើម្បីតាមដានប្រសិទ្ធភាពនៃការឆ្លើយតបវិស័យសុខាភិបាល និងដើម្បីចាត់វិធានការសមស្រប។ ផលិតរបាយការណ៍ស្ថានភាព ព្រឹត្តិបត្រ និងរបាយការណ៍ដទៃទៀតជូនទៅដៃគូ។ |
| | **ផែនការ៖** អនុមុខងារផែនការ ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួល ការធ្វើផែនការឆ្លើយតប ស្តារ និង/ឬបម្រុង និងរៀបចំផែនការសម្រាប់ការរំសាយ។ អនុមុខងារនេះកំណត់អំពីផលប៉ះពាល់ ដែលអាចកើតមាននាពេលអនាគតនៃគ្រោះអាសន្ន និងផ្តល់បច្ចុប្បន្នភាពតាមកាលវេលាកំណត់ អំពីបញ្ហាធ្វើផែនការជាមុន សម្រាប់អ្នកគ្រប់គ្រងឧប្បត្តិហេតុ និង IMT។ មុខងារនេះ រួមមានអនុមុខងារដូចខាងក្រោម ៖<br>- **ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការ៖** សម្របសម្រួលការរៀបចំបង្កើតផែនការជាក់លាក់តាមគ្រោះអាសន្ន ដោយមានធាតុចូលលម្អិតពីមុខងារដទៃទៀត ជាពិសេស ព័ត៌មានពីមុខងារប្រតិបត្តិការសុខភាព និងជំនាញបច្ចេកទេស។ អនុមុខងារនេះពាក់ព័ន្ធនឹងការរៀបចំបង្កើតនូវអាទិភាពជាយុទ្ធសាស្ត្ររួម វត្ថុបំណងប្រតិបត្តិការ និងផែនការរួម ព្រមទាំងការសម្របសម្រួលរឹងមាំនៅក្នុង និងរវាងវិស័យនានា។ |

| | |
|---|---|
| | - **ការគ្រប់គ្រងគម្រោង៖** គាំទ្រដល់ការរៀបចំផែនការគម្រោង រចនាសម្ព័ន្ធ និងខ្លឹមសារនៃព័ត៌មានពីម្ចាស់ជំនួយ និងរបាយការណ៍ផ្សេងទៀត តាមដានការអនុវត្តគម្រោង និងលើកកម្ពស់ការគ្រប់គ្រងដែលមានបទដ្ឋានត្រឹមត្រូវ នៅក្នុងវដ្តគម្រោងទាំងមូល។ |

**តារាងទី ៨៖ តួនាទីរបស់មុខងារប្រតិបត្តិការសុខភាព និងជំនាញបច្ចេកទេស**

| មុខងារសំខាន់ | បរិយាយអំពីតួនាទី |
|---|---|
| **ប្រតិបត្តិការសុខភាព និងជំនាញបច្ចេកទេស** ធ្វើការជាមួយក្រសួង ស្ថាប័ន និងជាមួយដៃគូនានា ដើម្បីធានានូវការគ្របដណ្តប់ និងគុណភាពសេវាសុខភាពល្អបំផុត នៅក្នុងការឆ្លើយតបទៅនឹងគ្រោះអាសន្ន។ មុខងារនេះធ្វើការដោយជំរុញការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈដែលជាក់លាក់តាមបរិបទ និងដែលមានប្រសិទ្ធភាពបំផុត ព្រមទាំងសេវាគ្លីនិកពីសំណាក់ដៃគូប្រតិបត្តិ។ មុខងារនេះផ្តល់ប្រតិបត្តិការនៅមូលដ្ឋានដែលផ្អែកតាមភ័ស្តុតាង គោលនយោបាយ ការណែនាំ និងជំនាញបច្ចេកទេស។ មុខងារនេះមានអនុមុខងារមួយចំនួនផងដែរ៖ | **វិធានការបង្ការ និងគ្រប់គ្រង៖** អនុមុខងារនេះកំណត់ និងបង្កើតនូវអនុសាសន៍ច្បាស់លាស់ ផ្សព្វផ្សាយការណែនាំ និងផ្តល់ជំនួយបច្ចេកទេស ស្តីពីវិធានការពាក់ព័ន្ធបំផុតដើម្បីបង្ការ និង/ឬគ្រប់គ្រងហានិភ័យសុខភាពសាធារណៈ ៖. បង្កើនការឃ្លាំមើល សេវាមន្ទីរពិសោធន៍នៅចំណុចថែទាំ ការដឹកជញ្ជូនសំណាក និងការធ្វើតេស្តមន្ទីរពិសោធន៍ឯកទេស យុទ្ធនាការចាក់វ៉ាក់សាំង វិធីការពារជំងឺទ្រង់ទ្រាយធំ ការគ្រប់គ្រងគ្លីនិក (និងការគ្រប់គ្រងទំនាក់ទំនងក្នុងករណីនៃការផ្ទុះជំងឺឆ្លង) ការបង្ការ និងគ្រប់គ្រងជំងឺឆ្លង ការបង្កើនសេវាទឹកស្អាត និងអនាម័យ សុវត្ថិភាពចំណីអាហារ និងសេវាអាហារូបត្ថម្ភ ការផ្គត់ផ្គង់ឱសថ និងសម្ភារៈវេជ្ជសាស្ត្រ។ ក្រុមឆ្លើយតបបន្ទាន់ នឹងត្រូវដាក់ពង្រាយដើម្បីអនុវត្តនូវវិធានការទាំងនេះ។<br><br>**ការប្រាស្រ័យទាក់ទងព័ត៌មានអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍៖** អនុមុខងារនេះ វាយតម្លៃបរិបទសង្គម និងវប្បធម៌របស់ប្រជាជនដែលប្រឈមនឹងហានិភ័យ ជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន បង្កើតសារមានសម្រួលទិសដៅច្បាស់លាស់ សម្រាប់ការផ្សព្វផ្សាយ ដោយធានាថា សារទាំងនោះត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងសមស្របទៅតាមបរិបទសង្គម និងវប្បធម៌ និងអនុវត្តការស្ទង់មតិរហ័ស និងការវាយតម្លៃផ្សេងៗទៀត ដើម្បីកំណត់ឧបសគ្គដែលរារាំងដល់ការអនុវត្តដំបូន្មានសុខភាព។ អនុមុខងារនេះបញ្ជូនសារអំពីសុខភាព ដោយប្រើប្រាស់មធ្យោបាយដែលមានប្រសិទ្ធភាពបំផុត ទៅតាមការនិយមរបស់ប្រជាជនគោលដៅ ជាភាសាក្នុងស្រុក និងតាមដានប្រសិទ្ធភាពនៃការផ្សព្វផ្សាយសារទាំងនោះ។<br><br>**ផ្តល់សេវាសុខភាព៖** អនុមុខងារនេះធានាការផ្តល់សេវាចាំបាច់ដល់ប្រជាជនដែលរងផលប៉ះពាល់។ អនុមុខងារនេះក៏ពាក់ព័ន្ធផងដែរ នូវការបញ្ជាក់ពីបទដ្ឋាន និងការកំណត់អត្តសញ្ញាណ កញ្ចប់សេវាសុខភាពសំខាន់ចាំបាច់ ដែលគ្របដណ្តប់ទាំងការផ្សព្វផ្សាយអប់រំទៅដល់សហគមន៍ និងការផ្តល់ការថែទាំសុខភាពនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ អនុមុខងារនេះ ក៏មើលខុសត្រូវទៅលើការគ្រប់គ្រងករណី ដោយធានាលទ្ធភាពអាចរក |

| | |
|---|---|
| | បានសមស្របនូវកម្លាំងសុខាភិបាលជំនាញ និងធនធានរូបវន្ត ដើម្បីបំពេញតម្រូវការជាមូលដ្ឋាន។ មើលខុសត្រូវលើការចែកចាយកញ្ចប់ និងសម្ភារៈវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់។<br><br>**ជំនាញបច្ចេកទេស វិទ្យាសាស្ត្រ និងការស្រាវជ្រាវ៖** អនុមុខងារនេះកំណត់រកចំណុចខ្វះចន្លោះផ្នែកចំណេះដឹងអំពីមូលហេតុជំងឺ សរីរោគវិទ្យា ការចម្លងរោគ ការធ្វើរោគវិនិច្ឆ័យ ព្រមទាំងការបង្ការ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវហានិភ័យ និងបុព្វហេតុនៃការឆ្លងជំងឺ និងការស្លាប់ច្រើនលើសលប់ និងផ្តល់ដំបូន្មានផ្នែកសុខភាពដែលផ្អែកតាមភ័ស្តុតាង។<br><br>**បណ្តុះបណ្តាលបុគ្គលិកសុខាភិបាល៖** អនុមុខងារនេះគាំទ្រដល់ការបណ្តុះបណ្តាលបុគ្គលិកជាតិដែលមានស្រាប់ និងបុគ្គលិកបន្ថែម ដែលអាចនឹងត្រូវតម្រង់ទិសសាជាថ្មី ដើម្បីអនុវត្តការឆ្លើយតបចំពោះគ្រោះអាសន្ន។ |

**តារាងទី ៩៖ តួនាទីនៃមុខងារគាំទ្រប្រតិបត្តិការ និងភស្តុភារ**

| មុខងារសំខាន់ | បរិយាយអំពីតួនាទី |
|---|---|
| **ការគាំទ្រប្រតិបត្តិការ និងភស្តុភារ**<br>មុខងារនេះធានាថាភាពជាដៃគូត្រូវបានប្រើប្រាស់ ដើម្បីធានាការគាំទ្រប្រតិបត្តិការ និងភស្តុភារប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលសម្រាប់ការឆ្លើយតបគ្រោះអាសន្ន។ នៅក្រោមមុខងារនេះ មានអនុមុខងារចំនួន ៣៖ | **ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់៖** អនុមុខងារនេះធានានូវការផ្តល់ដល់ទីកន្លែង ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធផល នូវសម្ភារៈប្រើប្រាស់ និងឧបករណ៍នានា ដើម្បីគាំទ្រដល់ប្រតិបត្តិការឆ្លើយតបគ្រោះអាសន្ន ក្នុងនោះរាប់ទាំងការជ្រើសរើស ការព្យាករណ៍ លទ្ធកម្ម ការដឹកជញ្ជូន ការវេចខ្ចប់បែបបទគយ ការរក្សាទុកដាក់ក្នុងឃ្លាំង និងការចែកចាយទ្រព្យសម្ភារៈទាំងអស់នេះ។<br><br>**ការគាំទ្រនៅថ្នាក់មូលដ្ឋាន៖** អនុមុខងារនេះផ្តល់យុទ្ធសាស្ត្រភស្តុភារ ការគ្រប់គ្រង និងការគាំទ្រនៅថ្នាក់មូលដ្ឋាន ទៅដល់ក្រុមឆ្លើយតប ក្នុងនោះរាប់ទាំងការស្នាក់នៅប្រកបដោយសុវត្ថិភាព ទីកន្លែងធ្វើការដែលមានសន្តិសុខ និងអាចដំណើរការទៅរលូន ព្រមទាំងឧបករណ៍ សមត្ថភាពគមនាគមន៍ ការដឹកជញ្ជូនដោយសុវត្ថិភាព និងការគ្រប់គ្រងក្បួនដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព។<br><br>**ភស្តុភារសុខាភិបាល៖** អនុមុខងារនេះ ផ្តល់នូវជំនាញផ្នែកបច្ចេកទេស ឧបករណ៍ វិធីសាស្ត្រ និងមធ្យោបាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ភស្តុភារជាក់លាក់នៃការឆ្លើយតប ក្នុងនោះរាប់ទាំងបរិក្ខារវេជ្ជសាស្ត្រ គាំទ្រការគ្រប់គ្រងប្រព័ន្ធត្រជាក់ មន្ទីរពិសោធន៍ និងធនាគារឈាម។ |

**តារាងទី ១០៖ តួនាទីនៃមុខងារហិរញ្ញវត្ថុ និងរដ្ឋបាល**

